**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សម្តេចព្រះមហាសុមេធាធិបតី
ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
លេខ:..០០៥/...........ស.ន.ក.ជ
/០៦

# ព្រះសង្ឃប្រកាស
## ស្តីពី
## ការកំណត់បែងចែកភារកិច្ចគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា

## សម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៦/២០៧ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញ អនុក្រឹត្យលេខ ៩៧៦ អនក្រ/តត ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០០៦ ស្តីពីការបង្កើតថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា.
- បានឃើញ សង្ឃប្រកាសលេខ ០០១/០៦ មស.រធត ចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០០៦ ស្តីពីការកំណត់បែងចែកភារកិច្ចសម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជ និងសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយក
- យោងតាមស្មារតីអង្គប្រជុំថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៦ ស្តីពីដំណើរការប្រព្រឹត្តិទៅ នៃវិស័យព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា.
- យោងតាមសំណូមពរ និងតម្រូវការចាំបាច់

## ស ម្រេ ច

ប្រការ ១- កំណត់បែងចែកព្រះភារកិច្ចប្រគេន មន្ត្រីសង្ឃជាន់ខ្ពស់ក្នុងជួរគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា ដូចតទៅនេះ :

* <u>ព្រះភារកិច្ចរបស់សម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត ព្រះសង្ឃនាយក</u>

- ទទួលភារកិច្ចស្តីទី ក្នុងការគ្រប់គ្រង និងដឹកនាំការងារពុទ្ធសាសនា ក្នុងឱកាសអវត្តមានសម្តេចព្រះអគ្គមហាសង្ឃ រាជាធិបតី សម្តេចព្រះមហាសង្ឃរាជនៃព្រះរាជាណាចក្រកម្ពុជា។
- តែងតាំងលោកគ្រូចៅអធិការ គ្រូសូត្រស្តាំ-ឆ្វេង ព្រះវិន័យធរ លេខាធិការ ព្រះឧបជ្ឈាយ៍ ព្រះវិន័យធរអនុគណ ព្រះធម្មធរអនុគណ ព្រះសមុហ៍អនុគណ ព្រះលេខាធិការអនុគណ តាមសំណើ របស់សមូហភាពសង្ឃនៃវត្តនីមួយៗ ដែលរួមមានទាំងព្រះអនុគណ ព្រះបាឡាត់គណ ព្រះមេគណ ដោយមានការយល់ ព្រមពីអាជ្ញាធរមូលដ្ឋាន ស្រុក-ខ័ណ្ឌ និងខេត្ត-ក្រុង តាមរយៈក្រសួងធម្មការនិងសាសនា ដោយត្រូវរាយការណ៍ថ្វាយ សម្តេចព្រះអគ្គមហាសង្ឃរាជាធិបតី សម្តេចព្រះមហាសង្ឃរាជទ្រង់ជ្រាប ។
- ទទួលព្រះភារកិច្ច ក្តាប់ការងារស្ថិតិវត្តអារាម ភិក្ខុ សាមណេរ អាចារ្យ គណៈកម្មការវត្ត កុមារ យុវជន ស្នាក់នៅក្នុងវត្ត នៅក្នុងទូទាំងប្រទេស បូកសរុបរាយការណ៍ថ្វាយសម្តេចព្រះអគ្គមហាសង្ឃរាជាធីបតី សម្តេចព្រះមហាសង្ឃរាជ ការបើកអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃប្រចាំឆ្នាំ ត្រួតពិនិត្យដំណើរការប្រព្រឹត្តទៅនៃវិស័យព្រះពុទ្ធសាសនា ក្នុងក្របខ័ណ្ឌកិច្ចការរដ្ឋបាល និងទំនាក់ទំនងសាធារណៈ។
- ទទួលព្រះភារកិច្ច ក្តាប់ការងារពុទ្ធិកសិក្សាគ្រប់កម្រិត ចាប់ពីពុទ្ធិកបឋមសិក្សារហូតដល់ពុទ្ធិកឧត្តមសិក្សានិងក្រោយពុទ្ធិកឧត្តមសិក្សាទូទាំងប្រទេស ក្នុងឋានៈជា អគ្គាធិការពុទ្ធិកសិក្សាជាតិ និងជាពុទ្ធិកសាកលវិទ្យាធិការនៃពុទ្ធិកសាកលវិទ្យាល័យ ដោយត្រូវផ្តោតព្រះទ័យទៅលើការពង្រឹង គុណភាព នៅសាលាពុទ្ធិកបឋមសិក្សានៅថ្នាក់មូលដ្ឋាន មានបញ្ហាគ្រូ បញ្ហាសម្ភារៈបរិក្ខារ កម្មវិធីសិក្សា ។ល។ និងសាលា ធម្មវិន័យទាំង៣ថ្នាក់ ។ / 

* ព្រះភារកិច្ចសម្តេចព្រះធម្មលិខិត លាស់ ឡាយ ព្រះសង្ឃនាយករងទី១ :

- ទទួលព្រះភារកិច្ចស្តីទី ក្នុងការគ្រប់គ្រង និងដឹកនាំការងារព្រះពុទ្ធសាសនា ក្នុងឱកាសអវត្តមានសម្តេចព្រះមហាសុមេធាធិបតី នន្ទ ង៉ែត ព្រះសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា ។
- ទទួលភារកិច្ច ជាប្រធានថេរសភា នៃព្រះពុទ្ធសាសនា នៅព្រះរាជាណាចក្រកម្ពុជា ។
- ទទួលភារកិច្ច ត្រួតពិនិត្យនូវរាល់អត្ថបទ ឯកសារ ធម៌ទេសនា សំដែងតាមវិទ្យុ ទូរទស្សន៍ និងសៀវភៅធម៌ទាំងឡាយ ដែលត្រូវបោះពុម្ពផ្សាយ ។

* ព្រះភារកិច្ចសម្តេចព្រះពោធិវង្ស អំ លឹមហេង ព្រះសង្ឃនាយករងទី២

- ទទួលព្រះភារកិច្ចការងាររដ្ឋបាល គ្រប់គ្រងត្រា ការងារលិខិតស្នាម ទំនាក់ទំនងសាធារណៈជាមួយបណ្តាក្រសួង ស្ថាប័ន អង្គភាព និងខេត្ត-ក្រុង ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា ទាំងផ្នែកពុទ្ធចក្រ និងទាំងផ្នែកអាណាចក្រ ។
- ជួយក្តាប់ស្ថិតិវត្តអារាម ភិក្ខុសាមណេរ សីលវន្ត សីលវតី អាចារ្យ គណៈកម្មការ ចាស់ព្រឹទ្ធាចារ្យ កុមារ យុវជន ស្នាក់នៅវត្ត នៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា បូកសរុបរាយការណ៍ប្រគេនសម្តេចព្រះមហាសុមេធាធិបតី ព្រះសង្ឃនាយកប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ

* ព្រះភារកិច្ចសម្តេចព្រះវនរ័ត ណយ ជ្រឹក ព្រះសង្ឃនាយករងទី៣

- ជួយបំពេញព្រះភារកិច្ចរាល់ការងារចាត់តាំង តម្លើងឋានៈ ដកចេញតួនាទី ត្រួតពិនិត្យ ការសុំអនុញ្ញាតបំបួសកុលបុត្រ (ភិក្ខុ សាមណេរ) ការសាងសង់សំណង់សំខាន់ៗ រៀបចំវត្តអារាម បរិស្ថាននៃវត្តនិមួយៗ ស័ក្តសមជាអារាម គួរគោរពបូជា ដោយជ្រះថ្លា រក្សាបេតិកភ័ណ្ឌជាតិ បេតិកភ័ណ្ឌសាសនា ប្រពៃណីទំនៀមទំលាប់ អារ្យធម៌ វប្បធម៌ជាតិ
- ជួយការងារតែងតាំង គ្រូសូត្រស្តាំ-ឆ្វេង ចៅអធិការ ព្រះឧបជ្ឈាយ៍ ព្រះវិន័យធរអនុគណ ព្រះធម្មធរអនុគណ ព្រះសមុហ៍អនុគណ ព្រះលេខាធិការអនុគណ និង ការកសង្ឃនៃវត្តនិមួយៗ ក្នុងកម្រិតថ្នាក់ស្រុក ខ័ណ្ឌ ឃុំ សង្កាត់

<u>ប្រការ</u> ២- សម្តេចព្រះសង្ឃនាយក សម្តេចព្រះនាយករងគ្រប់អង្គ មានសហការីមួយចំនួនជាជំនួយការ តាមតំរូវការជាក់ស្តែងនៃភារកិច្ចមួយអង្គៗ និងទទួលបំពេញភារកិច្ចបន្ថែមតាមតម្រូវការរបស់សម្តេចព្រះសង្ឃនាយក ។

<u>ប្រការ</u> ៣- គណៈសង្ឃនាយកគ្រប់អង្គ ធ្វើការងារដោយកិច្ចសហការជិតស្និទ្ធ ក្នុងជំហរសាមគ្គីភាព ជាសហធម្មិក តាមភារកិច្ចដែលបានកំណត់ ឱ្យប្រព្រឹត្តទៅទទួលបានជោគជ័យ និងលទ្ធផលល្អប្រសើរ ។

<u>ប្រការ</u> ៤- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការពាក់ព័ន្ធ គ្រប់ខេត្ត-ក្រុង និងមន្ត្រីសង្ឃគ្រប់ជាន់ថ្នាក់ ត្រូវអនុវត្តតាមព្រះសង្ឃប្រកាសនេះ ។

<u>ប្រការ</u> ៥- បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីព្រះសង្ឃប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

<u>ប្រការ</u> ៦- ព្រះសង្ឃប្រកាសនេះ មានប្រសិទ្ធភាព និងស្ថេរភាព ចាប់ពីថ្ងៃចុះព្រះហស្តលេខា [illegible] លេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៧ ព.ស ២៥៥០ / គ.ស ២០០៦

សម្តេចព្រះមហាសុមេធាធិបតី

ព្រះសង្ឃនាយក

នន្ទ ង៉ែត

លេខ : ០៧ ព្រស-បក

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៧ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចម្លងជូន</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ